# សាលាកប័ត្រព័ត៌មាន ៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា

**ទិដ្ឋភាពរួម ៖** ចាប់តាំងពីមានការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ មកអ្នកជំនាញរបស់អង្គការសហប្រជាជាតិ (អ.ស.ប) បានប្រមាណអំពីការកើនឡើងនៃការបណ្តេញចេញដោយបង្ខំដែលជាការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ សលាកប័ត្រពត៌មាននេះនឹងពិនិត្យមើលអំពីការបណ្តេញចេញដោយបង្ខំនៅកម្ពុជា និងកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ និងក្រុមហ៊ុនសាជីវកម្មត្រូវធ្វើការការពារទល់នឹងការបណ្តេញចេញដោយបង្ខំនោះ។ សាលាកប័ត្រពត៌មាននេះក៏នឹងពិនិត្យមើលផងដែរទៅលើការបណ្តេញចេញដោយបង្ខំក្នុងកំឡុងពេលកូវីដ១៩ និងការផ្តល់ជាអនុសាសន៍ជាក់ស្តែងដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ឈប់ការបណ្តេញចេញដោយបង្ខំ និងធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិដីធ្លី និងសេរីភាពមូលដ្ឋាននៅកម្ពុជា។

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ សេដ្ឋកិច្ចរបស់កម្ពុជាហាក់មានភាពលូតលាស់ល្អប្រសើរ ដែលធ្វើឲ្យកើនឡើងនូវតម្លៃដី ទំហំនៃការអភិវឌ្ឍន៍នានា និងការផ្តល់សម្បទានដីសេដ្ឋកិច្ច និងនៅតំបន់សេដ្ឋកិច្ចពិសេសទៅក្រុមហ៊ុនសារជីវកម្មក្នុងស្រុក និងអន្តរជាតិជាច្រើន។ ជាលទ្ធផល ទំនាស់ដីធ្លីហាក់មានសន្ទុះយ៉ាងខ្លាំងនៅកម្ពុជា និងធ្វើឲ្យមានការកើនឡើងនូវការបណ្តេញចេញដោយបង្ខំ និងការផ្លាស់ប្តូរទីលំនៅជារៀងរាល់ឆ្នាំ ដែលមានមនុស្សចំនួនមិនតិចទេត្រូវបានបណ្តេញចេញ ឬផ្លាស់ទី។ ថ្វីបើមានការការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ តែការបណ្តេញចេញដោយបង្ខំ នៅតែកើតមានឡើងជាបន្តបន្ទាប់និងមានការសន្និដ្ឋានថាមានមនុស្សប្រមាណជាងកន្លះលាននាក់ ត្រូវបានបណ្តេញចេញដោយបង្ខំចាប់តាំងពីឆ្នាំ២០០៣។[១] លើសពីនេះទៅទៀតចាប់តាំងពីមានជំងឺរាត្បាតកូវីដ១៩ អ្នកជំនាញរបស់អង្គការសហប្រជាជាតិបានកត់សម្គាល់ឃើញថាមានការកើនឡើងនៃការបណ្តេញចេញដោយបង្ខំទូទាំងពិភពលោក ហើយកម្ពុជាក៏មានករណីស្រដៀងគ្នាដែរ គឺមានប្រជាពលរដ្ឋរាប់រយគ្រួសារត្រូវបានរាយការណ៍ថា ត្រូវបានបណ្តេញចេញដោយបង្ខំចាប់តាំងពខែមករា ឆ្នាំ២០២០។[២]

ការបណ្តេញចេញដោយបង្ខំគឺជាការរំលោភបំពានសិទ្ធិមនុស្ស ដែលជាហេតុធ្វើឱ្យមានប្រជាពលរដ្ឋគ្មានផ្ទះសម្បែង និងមិនអាចរកប្រាក់ចញ្ចឹមជីវិត ធ្វើឱ្យមានវិសមភាពកាន់តែកើនឡើងខ្លាំង និងប៉ះពាល់ដល់ពលរដ្ឋក្រីក្រ និងសហគមន៍ងាយរងគ្រោះ។ សាលកប័ត្រព័ត៌មាននេះ ក៏នឹងពិនិត្យមើលអំពីការបណ្តេញចេញ

[១] ហ្សែនគ្រីនវូឌ 'ការបណ្តេញនៅកម្ពុជានៅតែត្រូវបានបន្តត្រួតពិនិត្យ' (ក្លូបប៊ិលប៉ុស្តិ៍ ២២ មករា ២០១២ (https://www.pri.org/stories/2012-01-22/cambodia-evictions-continue-unchecked.

[២] សម្រាប់ព័ត៌មានលំអិត មើលចំណុចទី៦ 'ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាក្នុងកំឡុងពេលកូវីដ១៩

ដោយបង្ខំ និងកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្សរបស់រដ្ឋ និងក្រុមហ៊ុនសាជីវកម្ម ដើម្បីការពារដល់បុគ្គល និងសហគមន៍រួចផុតពីការបណ្ដេញចេញដោយបង្ខំនោះ។ សាលកប័ត្រព័ត៌មាននេះក៏នឹងពិនិត្យមើលផងដែរអំពីការបណ្ដេញចេញដោយបង្ខំក្នុងកំឡុងពេលកូវីដ១៩ នៅទូទាំងពិភពលោកនិងកម្ពុជា ព្រមទាំងផ្ដល់អនុសាសន៍ជាក់ស្ដែងដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិមានដីធ្លី និងការពារឱ្យរួចផុតពីការបណ្ដេញចេញដោយបង្ខំនៅកម្ពុជា។



## តើអ្វីទៅជាការបណ្ដេញចេញដោយបង្ខំ?

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ បានកំណត់និយមន័យនៃការបណ្ដេញចេញដោយបង្ខំថា "ការជម្លៀសបុគ្គល គ្រួសារ និង/ឬសហគមន៍ជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ចេញពីផ្ទះ និង/ឬដីធ្លីរបស់ពួកគេដែលកំពុងកាន់កាប់ ដែលផ្ទុយពីឆន្ទៈរបស់ពួកគាត់ ដោយគ្មានការផ្ដល់ និងការទទួលបាននូវទម្រង់សមស្របនៃការការពារស្របច្បាប់ឬទម្រង់ការពារផ្សេងទៀត"។[៣] **កាបណ្ដេញចេញដោយបង្ខំគឺជាការរំលោភច្បាប់សិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។** ការបណ្ដេញចេញដោយបង្ខំ មិនត្រឹមតែរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមានលំនៅឋានប៉ុណ្ណោះទេ ប៉ុន្តែក៏បានរំលោភទៅលើសិទ្ធិជាច្រើនទៀតដែលទទួលស្គាល់ដោយច្បាប់ អន្តរជាតិ រួមមានសិទ្ធិរស់រានមានជីវិត សិទ្ធិសន្តិសុខរបស់បុគ្គល និងសិទ្ធិជនជាតិដើមភាគតិចទាក់ទងនឹងដីប្រពៃណី និងតំបន់របស់ពួកគាត់រស់នៅ ដែលនឹងធ្វើសេចក្ដីពន្យល់ក្នុងផ្នែកច្បាប់ នៃសាលកប័ត្រព័ត៌មាននេះ។[៤]

ការការពារឱ្យរួចផុតពីការបណ្ដេញចេញដោយបង្ខំ គឺមិនសំដៅតែទៅលើសុវត្ថិភាពកាន់កាប់ដីធ្លីរបស់បុគ្គលម្នាក់នោះទេ ប៉ុន្តែត្រូវជានាចំពោះបុគ្គលទាំងអស់ រួមទាំងអ្នកទាំងឡាយដែលរស់នៅលើ ទីតាំងមិនទាន់ផ្លូវការ ទីជនបទ និងអ្នកជួលផងដែរ។[៥] ក្នុងខណៈដែលការបណ្ដេញចេញដោយបង្ខំត្រូវបានអនុញ្ញាតដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងកាលៈទេសៈជាក់លាក់ណាមួយ (ឧទាហរណ៍៖ ការមិនបានបង់ប្រាក់ឈ្នួលយូរខែ) ការបណ្ដេញចេញ**ត្រូវតែអនុវត្តសមស្របតាមច្បាប់អនុញ្ញាត** និង**ត្រឹមត្រូវទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ** និងដំណោះស្រាយតាមនីតិវិធីច្បាប់មានសម្រាប់ជនរងគ្រោះ។[៦] មុនការបណ្ដេញចេញណាមួយត្រូវបានអនុវត្ត រដ្ឋត្រូវពិចារណាលើជម្រើសផ្សេងៗ ធ្វើតាមនីតិវិធីត្រឹមត្រូវ និងគោរពសិទ្ធិ

[៣] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មតិទូទៅលេខ៧ អំពីសិទ្ធិមានលំនៅឋានសមរម្យ ៖ ការបណ្ដេញចេញដោយបង្ខំ អ.ស.ប (១៩៩៧)ឯកសារ E/១៩៩៨/២២ កថាខ័ណ្ឌ៣

[៤] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស 'សាលកប័ត្រព័ត៌មានស្ដីពីការបណ្ដេញចេញដោយបង្ខំ លេខ២៥/ការពិនិត្យមើលឡើងវិញ១ ទំព័រ៥ (២០១៥) www.ohchr.org/Documents/Publications/FS25.Rev.1.pdf

[៥] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស 'ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្ត" ២០១៥ ទំព័រ៧ https://www.ohchr.org/Documents/Publications/Land_HR-StandardsApplications.pdf.

[៦] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ផ្នែកទី៣) កថាខ័ណ្ឌ១១

ទទួលព័ត៌មានពេញលេញ និងការពិគ្រោះយោបល់ត្រឹមត្រូវ និងការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ។ ការបណ្តេញចេញមិនត្រូវបណ្តាលឱ្យគ្មានផ្ទះសម្បែងនោះទេ[៧] ហើយគ្រប់ដំណាក់កាលទាំងអស់ត្រូវតែធានាថាមានការប៉ះពាល់តិចតួចបំផុតក្នុងការបណ្តេញចេញ ដោយមានការផ្តល់សំណងជាមុន និងត្រូវផ្តល់ដំណោះស្រាយដោយសមរម្យ។[៨]

ជាការទទួលខុសត្រូវរបស់រដ្ឋក្នុងការការពារឱ្យរួចផុតពីការបណ្តេញចេញដោយបង្ខំ និងមានការធានាថាការបណ្តេញចេញទាំងឡាយដែលបានអនុញ្ញាតនោះ ត្រូវធ្វើឡើងដោយស្របទៅតាមច្បាប់សិទ្ធិមនុស្ស និងត្រូវតែមានដំណោះស្រាយ។[៩] រដ្ឋក៏មានតួនាទីក្នុងការការពារបញ្ជៀសការបណ្តេញចេញដោយបង្ខំដោយភាគីទីបី រួមទាំងធុរកិច្ចផងដែរ។ **ធុរកិច្ចមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្ស** រួមទាំងមិនត្រូវមានការបណ្តេញចេញដោយបង្ខំទៅលើបុគ្គលទាំងឡាយឡើយ។[១០]

## ២. ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា

ការបណ្តេញចេញដោយបង្ខំបានកើតឡើងជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលការបណ្តេញចេញដោយបង្ខំត្រូវបានការពារនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅក្នុងប្រទេសកម្ពុជាក៏ដោយក៏នៅតែមានភាពខ្វះចន្លោះរវាងការការពារ និងការអនុវត្តជាក់ស្តែង ដែលធ្វើឱ្យទំនាស់ដីធ្លី ការរំលោភយកដីធ្លី និងការបណ្តេញចេញកាន់តែរីករាលដាល ឈានដល់ការរំលោភសិទ្ធិដីធ្លីជាប្រព័ន្ធនិងក្លាយជាបញ្ហាដ៏ធំមួយក្នុងចំណោមបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជានាសម័យទំនើបនេះ។[១១] ផ្នែកនៃដីធ្លីជាក់លាក់មួយចំនួនបច្ចុប្បន្ននេះត្រូវបានប្រើសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បង្កើតរោងចក្រ និងការដាំដុះ ព្រមទាំងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។ ជារឿយៗដីធ្លីត្រូវបានជួលឱ្យក្រុមហ៊ុនបរទេសនិងក្នុងស្រុក ព្រមទាំងអ្នកនយោបាយដែលមានអំណាចតាមរយៈសម្បទានដីសេដ្ឋកិច្ច ដែលក្នុងនោះដីធ្លីប្រមាណជាង២លានហិកតាត្រូវបានផ្តល់ ។[១២] ទាំងនេះជាបញ្ហានៅពេលបញ្ចូលជាមួយប្រព័ន្ធនៃការចុះបញ្ជីដីធ្លីរបស់កម្ពុជាដែលនៅមានកម្រិត រួមទាំងអសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងកង្វះខាតនៃកម្មសិទ្ធិស្របច្បាប់ និងនីតិរដ្ឋដែលមិនទាន់រឹងមាំបណ្តាលឱ្យមានការរឹបអូសយកដីធ្លី និងការបណ្តេញចេញដោយបង្ខំនៅតែបន្តកើតមាន។

[៧] ប្រភពដូចខាងលើ កថាខ័ណ្ឌ១៦

[៨] ឧទាហរណ៍ដំណោះស្រាយសមរម្យ, សូមមើលរបាយការណ៍របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្តផ្នែកទី៥ ទំព័រ២៩

[៩] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, សាលកប័ត្រព័ត៌មានស្តីពីការបណ្តេញចេញដោយបង្ខំ លេខ២៥/ការពិនិត្យមើលឡើងវិញទី១ (ដែលមាននៅក្នុងឯកសារយោងទី៤ នៃសាលកប័ត្រពត័ត៌មាននេះ)

[១០] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ដីធ្លី និងខ្នាតគំរូសិទ្ធិមនុស្ស និងការអនុវត្ត ផ្នែកទី៤ ទំព័រ៨១

[១១] ម.ស.ម.ក, ការទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិនានាពាក់ព័ន្ធនឹងបញ្ហាដីធ្លី ក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង https://cchrcambodia.org/admin/media/analysis/analysis/khmer/20181219%20BHR%20Briefing%20Note%20KHM-Final.pdf

[១២] លីកាដូ ‘ដីសម្បទានក្នុងប្រទេសកម្ពុជា’ (ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០) http://www.licadho-cambodia.org/land_concessions/.

គិតត្រឹមខែមីនា ឆ្នាំ២០១៤ ប្រជាពលរដ្ឋជាងកន្លះលាននាក់ត្រូវបានរាយការណ៍ថាបានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី។[១៣] ទោះបីជាមិនទាន់មានទិន្នន័យផ្លូវការស្តីពីការបណ្តេញចេញដោយបង្ខំក៏ដោយ ក៏មានការប៉ាន់ប្រមាណថានៅចន្លោះឆ្នាំ២០០៣ និងឆ្នាំ២០១២ មានប្រជាពលរដ្ឋកម្ពុជាប្រមាណ ៤០០.០០០ នាក់ត្រូវបានបណ្តេញចេញដោយបង្ខំ[១៤] ដោយក្នុងពេលបច្ចុប្បន្នចំនួននេះត្រូវបានគេរំពឹងថានឹងមានការកើនឡើង។ របាយការណ៍នាពេលថ្មីៗនេះរបស់សមាគមជាងត្នោតបានបង្ហាញថានៅក្នុងទីក្រុងភ្នំពេញមានប្រជាពលរដ្ឋជិត ១០.០០០ គ្រួសារ (ប្រមាណ ៤០.០០០ នាក់) ត្រូវបានបណ្តេញចេញដោយគ្មាននីតិវិធីត្រឹមត្រូវចាប់តាំងពីទសវត្សឆ្នាំ១៩៨០ មក។[១៥] របាយការណ៍ដែលបានចេញផ្សាយដោយ ម.ស.ម.ក បានពិនិត្យមើលទំនាស់ដីធ្លីចំនួន ៣ ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ១.៦០០ គ្រួសារ ហើយបានរកឃើញថាការបណ្តេញចេញដោយបង្ខំ និងដោយអំពើហិង្សាបានកើតឡើងគ្រប់ករណីទាំងអស់ ដោយផ្ទះរបស់ពលរដ្ឋត្រូវបានឈូសឆាយ និងដុតបំផ្លាញដោយអាជ្ញាធរនិងក្រុមហ៊ុន ហើយដីធ្លីនិងដំណាំត្រូវបានឈូសឆាយដោយគ្មានការជូនដំណឹងជាមុន និងការប្រើប្រាស់អំពើហិង្សា និងការគំរាមកំហែងដោយការចោទប្រកាន់ពីករណីព្រហ្មទណ្ឌចំពោះអ្នកការពារសិទ្ធិដីធ្លី ដែលជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។[១៦]

## ៣. ក្របខ័ណ្ឌច្បាប់ស្តីពីការបណ្តេញចេញដោយបង្ខំ

### *ច្បាប់អន្តរជាតិ*

ការការពាររួចផុតពីការបណ្តេញចេញដោយបង្ខំត្រូវបានចែងនៅក្នុងកម្រងសន្ធិសញ្ញាមួយចំនួនដែលកម្ពុជាបានផ្តល់សច្ចាប័ន រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។[១៧]

⇒ មាត្រា ១១ នៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ "រដ្ឋភាគីនៃកតិកាសញ្ញានេះដែលទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបនូវកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួនរួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ"។

[១៣] លីកាដូ 'ការកើនឡើងជាថ្មីនៃជម្លោះដីធ្លីគួរតែត្រូវបានដោះស្រាយជាបន្ទាន់ដោយមិនត្រូវបដិសេធឡើយ (ថ្ងៃទី១៥ ខែកម្ភៈ ឆ្នាំ២០២០) http://www.licadho-cambodia.org/pressrelease.php?perm=374&english.

[១៤] ហ្វែនគ្រីនវូឌ (មាននៅក្នុងឯកសារយោងទី១ នៃសាលាកប័ត្រព័ត៌មាននេះ)

[១៥] សមាគមជាងត្នោត, ការបណ្តេញចេញ និងការតាំងលំនៅថ្មី (ខែមករា ឆ្នាំ២០២០)http://teangtnaut.org/eviction_relocation_site_report/?lang=en

[១៦] ម.ស.ម.ក (មាននៅក្នុងឯកសារយោងទី១១ នៃសាលាកប័ត្រព័ត៌មាននេះ)

[១៧] សម្រាប់ព័ត៌មានបន្ថែមស្តីពីសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋនៅក្នុងច្បាប់អន្តរជាតិទាក់ទងនឹងការបណ្តេញចេញដោយបង្ខំ សូមមើល ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ 'គោលការណ៍ជាមូលដ្ឋាន និងមគ្គុទេសក៍ស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកកលើការអភិវឌ្ឍន៍ ឯកសាររបស់ អ.ស.ប (២០០៧) A/HRC/៤/១៨, https://www.ohchr.org/Documents/Issues/Housing/Guidelines_en.pdf.

⇒ មាត្រា ១៧ នៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយៈ"គ្មានជនណាម្នាក់ត្រូវបានជ្រៀតជ្រែកតាមអំពើចិត្តឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅឋាន សំបុត្រឆ្លងឆ្លើយរបស់ខ្លួនឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ" ។

ការបណ្តេញចេញដោយបង្ខំ ក៏អាចជាការរំលោភទៅលើសិទ្ធិរស់រានមានជីវិត សេរីភាពរួចចាកពីអំពើឃោរឃៅអមនុស្សធម៌និងថោកទាប និងសិទ្ធិសន្តិសុខផ្ទាល់ខ្លួន (កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយមាត្រា ៦, ៧ និង ៨) សិទ្ធិទទួលបានសុខភាព ការអប់រំនិងមានការងារធ្វើ (កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ មាត្រាទី ៦,១២ និង១៣) និងនៅមានសិទ្ធិច្រើនទៀត។[១៨] ការបណ្តេញចេញដោយបង្ខំទៅលើជនជាតិដើមភាគតិចគឺជាការរំលោភសិទ្ធិជនជាតិដើមភាគតិច និងគោលការណ៍នៃការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ។[១៩]

***ច្បាប់ជាតិ***

សន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់នេះ ត្រូវបានបញ្ចូលនៅក្នុងច្បាប់ជាតិតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ")។ លើសពីនេះ ច្បាប់ជាតិបានផ្តល់ការការពាររួចផុតពីការបណ្តេញចេញដោយបង្ខំផងដែរ។ ទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលឆ្នាំ២០០១ បានទទួលស្គាល់សិទ្ធិម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ហើយបានចែងថាការដកហូតដីធ្លី/ទ្រព្យសម្បត្តិអាចធ្វើបានតែក្នុងផលប្រយោជន៍សាធារណៈប៉ុណ្ណោះ និងតម្រូវឱ្យមានការផ្តល់ *សំណងដោយយុត្តិធម៌*ជាមុនផងដែរ។[២០] ច្បាប់ភូមិបាលបានផ្តល់សិទ្ធិភោគៈ សិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិនៅក្នុងកាលៈទេសៈជាក់លាក់[២១] និងវិធានការការពាររួចផុតពីការបណ្តេញចេញដោយបង្ខំចំពោះម្ចាស់កម្មសិទ្ធិឯកជននិងអ្នកកាន់កាប់ដីធ្លី។[២២] ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ ក៏បានតម្រូវឱ្យមានការផ្តល់សំណងដោយយុត្តិធម៌ផងដែរ។

[១៨] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, សាលកប័ត្រព័ត៌មានស្តីពីការបណ្តេញចេញដោយបង្ខំ លេខ២៥/ការពិនិត្យមើលឡើងវិញទី១ (មាននៅក្នុងឯកសារយោងទី៤ នៃសាលាកប័ត្រព័ត៌មាននេះ)

[១៩] ដូចមានចែងនៅក្នុង UNGA, ពិនិត្យឡើងវិញចំណុច A/61/L.67 'សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច' (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ មាត្រា១០) ។សម្រាប់ពត៌មានបន្ថែមស្តីពីគោលការណ៍នេះនៅ មក.ម.ស., 'សាលកប័ត្រព័ត៌មានស្តីពីគោលការណ៍ ការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ
http://business.sithi.org/upload/press_release/1502447868_en.pdf

[២០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៤៤ និងច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៥

[២១] ឧទាហរណ៍ មាត្រា៣០ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ផ្តល់សិទ្ធិស្នើសមប័ណ្ណកម្មសិទ្ធិចំពោះបុគ្គលណាដែលបានកាន់កាប់ដីឯកជនរបស់រដ្ឋ ដូចជាដីផ្ទះ ដោយសន្តិភាព អហិង្សា គ្មានទំនាស់ រយៈពេលប្រាំឆ្នាំមុនច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន

[២២] សូមមើលច្បាប់ភូមិបាលឆ្នាំ២០០១ ជំពូក៣

## ៤. ការបណ្ដេញចេញដោយបង្ខំក្នុងកំឡុងពេលកូវីដ១៩

ចាប់តាំងពីការផ្ទុះឡើងនៃកូវីដ១៩ នៅក្នុងខែមករា ឆ្នាំ២០២០ ការរំលោភសិទ្ធិដីធ្លី និងការបណ្ដេញចេញដោយបង្ខំត្រូវបានរាយការណ៍យ៉ាងច្រើននៅជុំវិញពិភពលោក នៅពេលដែលប្រជាពលរដ្ឋត្រូវការលំនៅឋាននិងសន្តិសុខបំផុត។[២៣] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមានលំនៅឋានសមរម្យបានបញ្ជាក់ជាថ្មីនៅថ្ងៃទី ២៨ ខែមេសាឆ្នាំ ២០២០ ថា រដ្ឋទាំងអស់ត្រូវតែធានាថាមនុស្សគ្រប់រូបត្រូវបានការពារឱ្យរួចផុតការបណ្ដេញចេញក្នុងអំឡុងពេលនេះ ពីព្រោះលំនៅឋានគឺជាអ្នកការពារជួរមុខប្រឆាំងនឹងមេរោគឆ្លងដោយបានពន្យល់ថា "*ការបណ្ដេញចេញដោយបង្ខំ គឺជាការបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិរួមទាំងសិទ្ធិរស់រានមានជីវិត ក៏ដូចជាការបណ្ដេញចេញណាមួយដែលបណ្ដាលឱ្យមានភាពគ្មានផ្ទះសម្បែងផងដែរ។ នៅកំឡុងពេលប្រឈមនឹងជំងឺរាតត្បាតនេះ ការបណ្ដេញចេញពីផ្ទះសម្បែងគឺប្រហាក់ប្រហែលនឹងការកាត់ទោសប្រហារជីវិត។ សិទ្ធិមានលំនៅឋានសមរម្យមិនមែនជាកម្មវត្ថុនៃការដកហូត ក្នុងគ្រាមានអាសន្ននោះទេ*"។[២៤] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមានលំនៅឋានសមរម្យ បានចេញផ្សាយកំណត់ត្រាណែនាំមួយ ស្ដីពីការហាមប្រាមការបណ្ដេញចេញក្នុងកំឡុងពេលកូវីដ១៩ និងបានផ្ដល់អនុសាសន៍ដល់រដ្ឋទាំងឡាយត្រូវមានវិធានការជាក់លាក់ការពារឱ្យរួចផុតពីការបណ្ដេញចេញរួមមាន ៖[២៥]

- បញ្ឈប់ជាបន្ទាន់នូវការបណ្ដេញចេញចំពោះបុគ្គលណាក៏ដោយ នៅគ្រប់ទីកន្លែងដោយហេតុផលណាមួយរហូតដល់កូវីដ១៩ ត្រូវបានធូរស្បើយ និងក្នុងពេលវេលាសមហេតុផល
- បញ្ចប់ការបណ្ដេញចេញដោយបង្ខំ ឬការផ្លាស់ប្ដូរលំនៅឋាននៃទីជម្រកមិនផ្លូវការទាំងអស់ និងធ្វើតាមការណែនាំដើម្បីការពារអ្នកតាំងលំនៅទាំងអស់នៅក្នុងទីជម្រកមិនផ្លូវការ និង
- ធានាឱ្យមានសិទ្ធិទទួលបានយុត្តិធម៌សម្រាប់បុគ្គលគ្រួសារឬសហគមន៍ដែលបានឆ្លងកាត់ការបណ្ដេញចេញរួចហើយ អាចស្វែងរកមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាព។

**ការបណ្ដេញចេញដោយបង្ខំនៅកម្ពុជាក្នុងកំឡុងពេលកូវីដ១៩**

ចាប់តាំងពីការចាប់ផ្ដើមនៃការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ ដែលបានចាប់ផ្ដើមជះឥទ្ធិពលដល់ប្រទេសកម្ពុជានៅចន្លោះខែមករា ដល់ ខែតុលា ឆ្នាំ២០២០ ការបណ្ដេញចេញដោយបង្ខំបានបន្តកើតមាននៅទូទាំងប្រទេស ឧទាហរណ៍រួមមាន ៖

[២៣] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ការហាមឃាត់ការបណ្ដេញចេញក្នុងកំឡុងពេលការរីករាលដាលនៃជំងឺកូវីដ១៩, ការជម្រុញរបស់អ្នកជំនាញរបស់ អ.ស.ប (ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០) www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=26170&LangID=E

[២៤] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមានលំនៅឋាន កូវីដ១៩ ការណែនាំ៖ ការហាមឃាត់ការបណ្ដេញចេញ (ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០)www.ohchr.org/Documents/Issues/Housing/SR_housing_COVID-19_guidance_evictions.pdf

[២៥] ប្រភពខាងដូចខាងលើ

- **នៅថ្ងៃទី២៤ ខែមេសា** អាជ្ញាធរបានឈូសឆាយទីតាំងមួយនៅបឹងសំរោង រាជធានីភ្នំពេញដែលមានប្រជាពលរដ្ឋ ១៨គ្រួសារ បានអះអាងថាពួកគាត់បានរស់នៅទីនោះតាំងពីឆ្នាំ១៩៧៩។ ខណៈដែលអាជ្ញាធររាយការណ៍ថាជាដីរបស់រដ្ឋ ក្រុមគ្រួសារដែលរងគ្រោះទាំងនោះបាននិយាយថាពុំមានការពិគ្រោះយោបល់ណាមួយឡើយហើយអាជ្ញាធរបានប្រើអំពើហិង្សាក្នុងការបណ្តេញចេញផងដែរ។[២៦]
- **នៅថ្ងៃទី២៤ ខែឧសភា** សហគមន៍ជនជាតិដើមភាគតិចចំនួន១២ ត្រូវបានបណ្តេញដោយបង្ខំចេញពីដីរបស់ពួកគេដោយក្រុមហ៊ុនចម្ការកៅស៊ូវៀតណាម ហ័ងអាញ យ៉ា ឡាយ ទោះជាមានការសន្យាថានឹងប្រគល់ដីនោះជូនសហគមន៍វិញតាំងពីខែកញ្ញា ឆ្នាំ២០១៥ ក៏ដោយ។ ក្រុមហ៊ុនចម្ការកៅស៊ូវៀតណាមបានឈូសឆាយពួកគាត់រួមទាំងដីអារក្ស ទីបរបាញ់ និងដីកប់សព។[២៧]
- **នៅថ្ងៃទី២៧ ខែឧសភា** អាជ្ញាធរបានអនុវត្តវិធានការណ៍ឈូសឆាយនិងរុះរើរបងនិងផ្ទះកុងតឺន័ររបស់គ្រួសារមួយនៅផ្លូវជាតិលេខ៦ ក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងរណបនៃក្រុមហ៊ុនសាជីវកម្មវិនិយោគក្រៅប្រទេសក្នុងកម្ពុជាដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ព្រែកលាភ ខណ្ឌជ្រោយចង្វារ ជាយរាជធានីភ្នំពេញ។ ការឈូសឆាយដីនេះបានធ្វើឡើងជាផ្នែកមួយនៃគម្រោងពង្រីកផ្លូវទោះជាម្ចាស់ដីមិនព្រមទទួលយកសំណងដែលបានផ្តល់ជូនក៏ដោយ។[២៨]
- **នៅថ្ងៃទី១១ ខែមិថុនា** គ្រួសារចំនួន១០០ ត្រូវបានបណ្តេញចេញដោយបង្ខំពីផ្ទះរបស់ពួកគេនៅលើបឹងតាមោករាជធានីភ្នំពេញដោយអាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានចាត់វិធានការនៅពេលព្រឹកព្រលឹមដោយពុំមានការជូនដំណឹងឬពិគ្រោះយោបល់អំពីការរុះរើផ្ទះទាំងនោះឡើយ។ ផ្ទះមួយចំនួនត្រូវបានដុតបំផ្លាញ។[២៩]
- **នៅថ្ងៃទី១១ ខែមិថុនា** អាជ្ញាធរខេត្តក្រចេះត្រូវបានគេរាយការណ៍ថាបានប្រើគ្រឿងចក្រឈូសឆាយផ្ទះរបស់ប្រជាពលរដ្ឋចំនួន៣ គ្រួសារ បន្ទាប់ពីពួកគេមិនព្រមលក់ដីរបស់ពួកគេទៅឱ្យក្រុមហ៊ុន រិទ្ធី ក្រានីត ខេមបូឌា ខូអិលធីឌី។ អ្នកភូមិមូលដ្ឋានបានរាយការណ៍ថាមានអ្នកភូមិចំនួន៣នាក់ ត្រូវបានចាប់ខ្លួនហើយអាជ្ញាធរបានគំរាមបាញ់សម្លាប់ប្រជាពលរដ្ឋដែលហ៊ានចេញមុខតវ៉ា។[៣០]

---

[២៦] សមាគមធាងត្នោតអំពាវនាវឱ្យមានការបញ្ចប់ការបណ្តេញចេញក្នុងកំឡុង កូវីដ១៩ ខែមករា ឆ្នាំ២០២០ )http://teangtnaut.org/eviction_relocation_site_report/?lang=en; ស៊ុន ណារីន 'របាយការណ៍បង្ហាញថាការបណ្តេញនៅភ្នំពេញធ្វើឱ្យមានបញ្ហា´) VOA, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០ https://khmer.voanews.com/a/ngo-report-shows-little-improvement-in-handling-of-land-evictions-/5481494.html

[២៧] អង្គការភីវឌ្ឍន៍ប្រកបដោយបរិយាប័ន្នអន្តរជាតិ )Inclusive Development International ('ក្រុមហ៊ុនកសិពាណិជ្ជកម្មវៀតណាម ហ័ងអាញ យ៉ាឡាយ ឈូសឆាយដីជនជាតិដើមភាគតិច´ (អង្គការភីវឌ្ឍន៍ប្រកបដោយបរិយាប័ន្នអន្តរជាតិ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០) https://www.inclusivedevelopment.net/vietnamese-agribusiness-giant-destroys-indigenous-lands/.

[២៨] ម.ស.ម.ក ការឃ្លាំមើលធុរកិច្ចនិងសិទ្ធិមនុស្ស (ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០) www.facebook.com/pg/cchrcambodia/photos/?tab=album&album_id=10163479754360431

[២៩] ប្រភពពីសមាគមធាងត្នោតខាងលើ

[៣០] យុត សុគុន្ធ "ពលរដ្ឋ៣នាក់ត្រូវអាជ្ញាធរខេត្តក្រចេះចាប់ខ្លួន និងឈូសឆាយផ្ទះក្រោយបដិសេធលក់ដីឱ្យក្រុមហ៊ុន´ (VOD ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០) https://vodkhmer.news/2020/06/11/three-kratie-villagers-arrested-clearing-houses-after-refusing-sell-their-land-company/.

- **នៅថ្ងៃ១២ ខែកក្កដា** ប្រជាពលរដ្ឋចំនួន១៥០គ្រួសារ ដែលរស់នៅក្នុងទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញត្រូវបានគេប្រាប់ឱ្យជម្លៀសនិងរុះរើផ្ទះសម្បែងរបស់ពួកគេចេញពីទីនោះដោយអាជ្ញាធរបានប្រាប់ថាពួកគេកំពុងរស់នៅលើដីសាធារណៈ។[៣១] ក្រុមគ្រួសាររាយការណ៍ថាបានរស់នៅទីនោះជាង ២០ឆ្នាំ មកហើយ។ ក្នុងចំណោមប្រជាពលរដ្ឋចំនួន ១៥០គ្រួសារ មាន ៥១គ្រួសារ មិនបានទទួលសំណងណាមួយឡើយ។
- **នៅថ្ងៃទី២០ ខែកក្កដា** អាជ្ញាធរបានប្រកាសថាខ្លួននឹងរុះរើសំណង់ទាំងអស់រួមទាំងផ្ទះ និងអាជីវកម្មដែលបានសង់រំលោភបំពានលើផ្លូវសាធារណៈក្នុងក្រុងព្រះសីហនុរួមមានយ៉ាងតិចផ្ទះចំនួន១៥ខ្នង/ក្បាលដីដើម្បីបើកផ្លូវសម្រាប់ការអភិវឌ្ឍផ្លូវថ្មីដោយមានការជូនដំណឹងមុនតែ១០ថ្ងៃ ប៉ុណ្ណោះ។[៣២]
- **នៅថ្ងៃទី២៣ ខែកញ្ញា** ឯកឧត្តមទៀបាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជាបានប្រកាសថាប្រជាពលរដ្ឋដែលរស់នៅខេត្តសៀមរាប ដែលប៉ះចំគម្រោងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍផ្លូវចំនួន ៣៨ខ្សែ ដែលមានចម្ងាយ១០០ គីឡូម៉ែត្រ នោះត្រូវតែរុះរើផ្ទះរបស់ពួកគេចេញពីទីនោះជាបន្ទាន់។ ឯកឧត្តមបាននិយាយថា នឹងពុំមានសំណងអ្វីទេចំពោះប្រជាពលរដ្ឋទាំងនោះពីព្រោះថាពួកគេបានរស់នៅលើដីរដ្ឋ។[៣៣] ពុំមានសេចក្តីរាយការណ៍អំពីចំនួនគ្រួសារដែលនឹងរងផលប៉ះពាល់ដោយគម្រោងនោះទេ ក៏ប៉ុន្តែមានសេចក្តីរាយការណ៍ថា មានប្រជាពលរដ្ឋប្រមាណជា ៣០០ ទៅ ៤០០ គ្រួសារនឹងត្រូវរុះរើសំណង់របស់ពួកគេ។[៣៤]

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការបណ្តេញចេញដោយបង្ខំជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ប៉ុន្តែជាអកុសលនៅតែបន្តកើតមានក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលប្រកាសភេរវសញ្ញានៃជំងឺរាតត្បាតកូវីដ១៩។ រាជរដ្ឋាភិបាលគួរដោះស្រាយនូវបញ្ហាដែលបានលើកឡើងខាងលើជាពិសេស ម.ស.ម.ក សូមផ្តល់ជូននូវអនុសាសន៍ដូចខាងក្រោម៖

១. បញ្ឈប់ជាបន្ទាន់**នូវរាល់ការបណ្តេញចេញដោយបង្ខំ និងការប្រើប្រាស់កម្លាំង**ដោយអាជ្ញាធររដ្ឋក្នុងការបណ្តេញចេញព្រមទាំងការពារឱ្យរួចផុតពីការបណ្តេញចេញដោយបង្ខំ និងការបង្ខិតបង្ខំដោយភាគីទីបី ជាពិសេសពីសំណាក់ធុរកិច្ច។

---

[៣១] ណា សុភាព ‘ប្រជាសហគមន៍ក្បែរផ្សារសុវណ្ណាស្នើសុំសំណងសមរម្យជាថ្នូររុះរើផ្ទះចេញ’ (VOD ខ្មែរ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២០) https://vodkhmer.news/2020/07/12/community-find-repay-for-eviction/.

[៣២] ប៊ិច សុធារី ‘ដប់ថ្ងៃទៀតអាជ្ញាធរខេត្តព្រះសីហនុ នឹងរោះរើសំណង់ដែលស្ថិតនៅលើចំណីផ្លូវសាធារណៈ’ (Khmer Times ថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០២០) https://www.khmertimeskh.com/50746611/ដបថងទត-អជញធរខត/.

[៣៣] គ្រប់សំណង់លើចំណីផ្លូវ៣៨ខ្សែនៅសៀមរាប ត្រូវតម្រូវឱ្យរុះរើចេញដោយមិនផ្តល់សំណង’ (ថ្មីៗ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០) https://thmeythmey.com/?page=detail&id=95874.

[៣៤] សុខ ស្រីលុច ‘សេចក្តីជូនដំណឹងដើម្បីរុះរើអាគារសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថ្មីទាក់ទាញការឆ្លើយតបចម្រុះ’ (Khmer Times ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២០) https://www.khmertimeskh.com/50767974/notice-to-remove-buildings-for-new-infrastructure-draws-mixed-response/.

២. **បញ្ឈប់រាល់ទម្រង់នៃការបណ្ដេញចេញក្នុងកំឡុងពេលនៃជំងឺរាតត្បាតកូវីដ១៩** ដោយពិចារណាប្រសិនបើអាចធ្វើបានលុះត្រាតែក្នុងរយៈពេលសមហេតុផលណាមួយនៅពេលខាងមុខដោយអនុលោមតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ។

៣. **អនុវត្តតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ ក្នុងកំណត់ត្រាណែនាំស្ដីពីកូវីដ១៩** ដែលហាមប្រាមការបណ្ដេញចេញ[៣៥] និងកំណត់ត្រាណែនាំស្ដីពីកូវីដ១៩ ដើម្បីការពារប្រជាពលរដ្ឋដែលស្ថិតនៅក្នុងទីជម្រកមិនផ្លូវការ[៣៦]។

៤. ធានាថារាល់ការបណ្ដេញចេញចាំបាច់ត្រូវគោរពតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសត្រូវធានាថា គ្រួសារទាំងអស់ត្រូវបានផ្ដល់**សំណងដោយសមរម្យ** ហើយការបណ្ដេញចេញអាចធ្វើបានលុះត្រាតែ**ក្នុងករណីជម្រើសចុងក្រោយបង្អស់** និង**ត្រូវហាមប្រាមការប្រើប្រាស់កម្លាំងហួសប្រមាណ**។

៥. ធានាថាការអនុវត្តការបណ្ដេញចេញចាំបាច់ណាមួយត្រូវអនុវត្តតាម**គោលការណ៍ជាមូលដ្ឋាន និង មគ្គុទេសក៍ស្ដីពីការបណ្ដេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែក លើការអភិវឌ្ឍន៍**[៣៧]។

៦. ធានាឱ្យមាន**ដំណោះស្រាយដ៏មានប្រសិទ្ធិភាពចំពោះការរំលោភសិទ្ធិមនុស្សទាំងឡាយណា**ដែល បណ្ដាលមកពីការបណ្ដេញចេញដោយបង្ខំ និងធានាថាដំណោះស្រាយទាំងនោះត្រូវគោរពតាមខ្នាតគំរូអន្តរជាតិ និងស្របតាមតម្រូវការនៃគោលការណ៍ទី៣១ នៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស។

៧. ធានាឱ្យមាន**ការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់** ត្រូវធ្វើឡើងមុនពេលបង្កើតកិច្ចសន្យានៃការអភិវឌ្ឍទាំងឡាយ និងត្រូវផ្ដល់ព័ត៌មានដល់សហគមន៍ដោយអនុលោមទៅតាម**គោលការណ៍ស្ដីពីការប្រឹក្សាយោបល់ត្រឹមត្រូវ និងការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ**។

៨. **បញ្ឈប់រាល់ទម្រង់នៃការឃ្លាំមើល ការយាយី និងការដាក់ទោសទណ្ឌ**ទៅលើអ្នកការពារសិទ្ធិមនុស្សទាក់ទងនឹងទំនាស់ដីធ្លី និងការបណ្ដេញចេញដោយបង្ខំ។ ព្រមទាំង**ដោះលែងសកម្មជនដីធ្លី**ដែលកំពុងជាប់ពន្ធនាគារដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំ។

---

[៣៥] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិមានលំនៅឋាន កូវីដ១៩ ការណែនាំ៖ ការហាមឃាត់ការបណ្ដេញចេញ (ដែលមាននៅក្នុងឯកសារយោងលេខ២៥ នៃសាលាកប័ត្រព័ត៌មាននេះ)

[៣៦] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស,កំណត់ត្រាណែនាំកូវីដ១៩ ការពារប្រជាពលរដ្ឋដែលរស់នៅក្នុងទីជម្រកមិនផ្លូវការ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ (ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០) https://www.ohchr.org/Documents/Issues/Housing/SR_housing_COVID-19_Guidance_informal_settlements.pdf.

[៣៧] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គោលការណ៍ជាមូលដ្ឋាន និងមគ្គុទេសក៍ស្ដីពីការបណ្ដេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកលើការអភិវឌ្ឍន៍ (ដែលមាននៅក្នុងឯកសារយោងលេខ១៧ នៃសាលាកប័ត្រព័ត៌មាននេះ)

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងអ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស របស់ ម.ស.ម.ក **លោក វណ្ណ សុផាត** តាមរយៈទូរស័ព្ទលេខ (+៨៥៥) (0) **១២ ៩៤១ ២០៦** ឬតាមរយៈអ៊ីមែល **vann.sophath@cchrcambodia.org** ។